**ស្វាគមន៍ឆ្នាំសិក្សា ២០១៦-២០១៧**

**នៅសាលាបឋមសិក្សា Henry C. Lea!**

ជូនចំពោះ មាតាបិតា/អាណាព្យាបាល៖

ខ្ញុំចូលធ្វើជានាយកសាលារបស់លោកអ្នក នៅសាលាបឋមសិក្សា Henry C. Lea ដោយក្តីរំភើបយ៉ាងក្រៃលែង។ បុគ្គលិកនៅសាលា លី (Lea) រង់ចាំឆ្នាំសិក្សាដែលមានភាពលូតលាស់ និង មានការចូលរួមជាមួយកូនលោកអ្នក។ ឆ្នាំនេះ យើងខ្ញុំនឹងខិតខំដើម្បីគាំទ្រដល់សេចក្តីត្រូវការទូទៅ និង សេចក្តីត្រូវការក្នុងការសិក្សា នៃសិស្សចម្រុះរបស់យើង។

ខ្ញុំប្តូរពីសាលាបឋមសិក្សា Kenderton នៅប៉ែកខាងជើងនៃទីក្រុងហ្វីឡាដែលហ្វ្យា មកធ្វើការនៅសាលា Lea នៅទីនោះ ខ្ញុំមានតំណែងជា នាយករងផ្នែកគាំទ្រសិស្ស។ ខ្ញុំបានចំណាយពេលបន្ត ការបង្ហាត់បង្រៀន ការងាររដ្ឋបាល និង ការបង្កើនបទពិសោធន៍ផ្នែកច្បាប់ ដើម្បីជួយបុគ្គលិករបស់យើងឲ្យទទួលបានលទ្ធផលល្អបំផុត សម្រាប់សិស្សរបស់យើង។ ខ្ញុំបានចំណាយពេលធ្វើការផ្នែកអប់រំនៅសាលារដ្ឋ និង ច្បាប់សាលា មុខតំណែងនៅឆ្នាំទីមួយរបស់ខ្ញុំជាគ្រូនៅ អនុវិទ្យាល័យ និង វិទ្យាល័យ នៃសាលារដ្ឋ និង សាលាឆាទ័រ នៃទីក្រុងហ្វីឡាដែលហ្វ្យា។ ក្រោយពីទទួលបាន សញ្ញាប័ត្របណ្ឌិតផ្នែកច្បាប់ (J.D.) ដំបូងខ្ញុំធ្វើជា មេធាវីរដ្ឋផ្នែកហិរញ្ញវត្ថុ ហើយក្រោយមកបានពង្រីកការងាររបស់ខ្ញុំ ដើម្បីរួមបញ្ចូល ច្បាប់សាលា និង ច្បាប់នៃការអប់រំ។ ហើយបន្ទាប់មក ខ្ញុំបានត្រឡប់មកចូលរួមក្នុងវិស័យអប់រំវិញ មានតំណែងជារដ្ឋបាលផ្នែកអប់រំពិសេសនៅក្រសួងអប់រំដែលស្ថិតនៅក្រៅក្រុងដ៏ធំមួយ និង អង្គការនៃសាលាឆាទ័រ មុនពេលចូលធ្វើការនៅសាលា Kenderton។

ខ្ញុំទទួល សញ្ញាប័ត្រអនុបណ្ឌិត ផ្នែកអប់រំសាលាបឋមសិក្សា ពីសាកលវិទ្យាល័យ ផិនស៊ីលវេនញ៉ា ថ្នាក់បណ្ឌិតផ្នែកអប់រំ សញ្ញាប័ត្របណ្ឌិតផ្នែកច្បាប់ ពីសាលាច្បាប់នៃសាកលវិទ្យាល័យ ផិនស៊ីលវេនញ៉ា និង សញ្ញាប័ត្រផ្នែកនាយកសាលា ពីសាកលវិទ្យាល័យ Saint Joseph។ ខ្ញុំក៏បានទទួល សញ្ញាប័ត្រផ្នែកនយោបាយ ពី Fels Institute of Government នៅសាកលវិទ្យាល័យ ផិនស៊ីលវេនញ៉ា។

បុគ្គលិកនៅសាលា លី (Lea) និងខ្លួនខ្ញុំផ្ទាល់ នឹងផ្តល់ឲ្យកូនលោកអ្នកនូវការអប់រំដែល មានសុវត្ថិភាព មានការគាំទ្រ និង ហ្មត់ចត់។ យើងខ្ញុំរង់ចាំសហការជាមួយលោកអ្នក នៅឆ្នាំសិក្សានេះ។

ដោយសេចក្តីស្ម័គ្រស្មោះ

ShaVon Savage, នាយកសាលា